# អង្គការសហការអន្តរជាតិ កម្ពុជា

INTERNATIONAL COOPERATION CAMBODIA



# របាយការណ៍ប្រចាំឆ្នាំ ២០១៤

## គុណតម្លៃស្នូលរបស់ ICC គឺ:

- មានលក្ខណៈបម្រើ; ចែកចាយសេចក្ដីស្រឡាញ់ និងការអត់ទោស
- ការយល់ដឹងពីវប្បធម៌; ចំពោះវប្បធម៌ជាតិ និងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា
- មានសេចក្ដីជំនឿក្នុងផ្នត់គំនិត; ទៅតាមទស្សនៈវិស័យ និងបេសកកម្មរបស់ ICC

## ពាក្យស្លោករបស់ ICC គឺ:

"ពង្រឹងសហគមន៍ ជាតិរឹងមាំ"

# ផ្នែកសំខាន់ៗសម្រាប់របាយការណ៍ឆ្នាំ២០១៤

ឆ្នាំ២០១៤បានក្លាយជាឆ្នាំដែលអង្គការ អាយស៊ីស៊ី បន្តជាថ្មីនូវទិសដៅយុទ្ធសាស្ត្រ ហើយឥឡូវនេះ យើងកំពុងតែលើកកំពស់ការយកចិត្តទុកដាក់ និងផ្តោតទៅលើផ្នែក ២ គឺសិទ្ធិមនុស្ស និងសហគមន៍/ ការបង្កើតក្រុម។ ទិសដៅនៃយុទ្ធសាស្ត្រថ្មីបាន កកើតឡើងក្នុងគម្រោង កម្មវិធីដែលដំណាក់កាលនិមួយៗត្រូវបានបន្ត និងក្នុងបែបផែនថ្មីនៃបទអន្តរាគមន៍ថ្មី។ វាជាការលើកទឹកចិត្តដោយឃើញក្រុមការងារនៃគម្រោងកម្មវិធីថ្មីបាន ផ្លាស់ប្តូរទិសដៅយុទ្ធសាស្ត្រថ្មីផ្អែកតាម ឧបករណ៍វាស់វែង ការអនុវត្តន៍ និងឃើញ ពីរបៀបចូលរួម ចំណែកដែលធ្វើ ឲ្យជីវិតកាន់តែប្រសើរឡើង ខាងផ្នែករាងកាយ សង្គម និងព្រលឹងវិញ្ញាណ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិកក្រុម នៃអង្គការ អាយស៊ីស៊ី ទាំងអស់ដែលរួមចំណែកក្នុងការងារអភិវឌ្ឍន៍ អាយស៊ីស៊ី ដោយក្តីមេត្តាករុណា និងវិជ្ជាជីវៈ ហើយគិតគូរដល់ផលប្រយោជន៍របស់សហគមន៍/អ្នកទទួលផល ជាសំខាន់។ ឆ្នាំ២០១៤គឺជាឆ្នាំដែលយើង បានចាប់ផ្តើមអភិវឌ្ឍភាសា ចារ៉ាយ ហើយយើងក៏ សូមថ្លែងអំណរគុណចំពោះ ការជួយគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងការ ជួយជំរុញលើការងារនេះមួយកំរិតទៀត។ ឆ្នាំ២០១៤ក៏ជាឆ្នាំដែលយើងចាប់ផ្តើម ស្វះស្វែងរកក្រុមថ្មីដែលសុទ្ធ សឹងជាអ្នកដែលគេគិតគូរតិចតួចនៅក្នុងប្រទេសកម្ពុជា ហើយ អាយស៊ីស៊ី កំពុងតម្រង់ទៅដល់ការចាប់ផ្តើមគម្រោងកម្មវិធីសាកល្បងដើម្បីគាំទ្រមនុស្សចាស់ និងក្រុមមនុស្សដែលទាក់ទងទៅនឹងការជួញដូរ។



ការងាររបស់យើងមិន អាចធ្វើទៅបាន ដោយគ្មានដៃគូរដ៏ស្មោះត្រង់ប្រកបដោយឆន្ទៈដែលអ្នក ទាំងនោះមិនគ្រាន់តែគាំទ្រយើងដោយផ្នែកហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែបានផ្តល់នូវ ជំនាញវិជ្ជាជីវៈ ហើយបាន ចូលរួមចំណែកគួរឲ្យកត់សំគាល់ដល់ការងាររបស់យើងទៀតផង។ លើសពីនេះ យើងសូមថ្លែង អំណរគុណដ៏ ជ្រាលជ្រៅចំពោះ ទំនាក់ទំនង ដ៏យូរអង្វែង និងជិតស្និទ្ធ នៃក្រសួងការបរទេស និងបណ្តាក្រសួងជាខ្សែរយៈដែលបាន រួមសហការ ជាមួយនឹងយើង ហើយកិច្ចសហការទាំងនោះបានផ្តល់នូវតម្លៃជាអនេកដល់កិច្ចការរបស់យើង។

ឆ្នាំ២០១៤ ជាឆ្នាំវិជ្ជមាននៃអង្គការ អាយស៊ីស៊ី ។ តាំងពីដំបូងនៃឆ្នាំនេះ អាយស៊ីស៊ី បានចាប់ផ្តើម អនុវត្តការងារទំនាក់ទំនងខាងក្រៅ ហើយជាលទ្ធផលយើងទទួលបានសមាជិក ១០នាក់ដែលជាអនុសមាជិក និងជាដៃគូរខាងក្រៅជាមួយប្រិយសម្ព័ន្ធពន្ធនាគារ (PFC) និងអង្គការម្លប់ឬស្សី (MRO) ។ នៅឆ្នាំ ២០១៤ នេះដែរ អាយស៊ីស៊ី បានចាប់ផ្តើម បង្កើតឲ្យមានកន្លែងពិសោធន៍ការងារ ក្នុងគោលបំណងលើកទឹកចិត្ត ឲ្យមានកម្មវិធីថ្មីៗ ក្នុងអង្គការអាយស៊ីស៊ី។ ទន្ទឹមនឹងនេះ អាយស៊ីស៊ី ក៏បានធ្វើការឆ្លុះបញ្ចាំង ទៅលើការផ្សារភ្ជាប់រចនាសម្ព័ន្ធនៃភ្នាក់ងារ បេសកកម្ម ជាមួយនឹង អង្គការផ្សេងៗ ដែលមាន សកម្ម ភាពប្រហាក់ ប្រហែលនៅអាស៊ី និងចែករំលែកបទពិ សោធន៍ពីការងារ ក្នុងការឆ្លើយតបទៅ នឹងបញ្ហាប្រឈម និងនិន្នាកា ផ្សេងៗ។

នៅក្នុងប្រទេសកម្ពុជា សិទ្ធមនុស្សគឺជាប្រធានបទរសើបមួយ និងជាញឹកញាប់មិន មានការបកស្រាយអោយបានត្រឹមត្រូវ។ ក្នុង មាត្រាទីមួយរបស់ UDHR សិទ្ធមនុស្សមាន ន័យថា *"មនុស្សទាំងអស់កើតមកមានសិទ្ធសេរីភាព ភាពថ្លៃថ្នូរ ហេតុផល និង មនសិកាដូចគ្នាហើយគួរប្រព្រឹត្តចំពោះគ្នាដូចជាបងប្អូន"*។ ទីណាមិនមានការគោរពសិទ្ធមុនស្សទីនោះនឹងងាយមានការកេងប្រវ័ញ្ចនិង រំលោភបំពាន។ បើមនុស្សមានការយល់ដឹងអំពីសិទ្ធមនុស្ស និងទំនួលខុសត្រូវរបស់ខ្លួនក្នុងនាមជាពលរដ្ឋម្នាក់ វាពិតជារួមចំណែកយ៉ាងច្រើនក្នុងការជួយសង្គមអោយមានរីកចំរើន និង ការទទួលខុសត្រូវ។ យើងឃើញថាសិទ្ធកុមារ និងសិទ្ធសហគមន៍ជនជាតិភាគតិចមិនទាន់បានទទួលស្គាល់ជាទូលំទូលាយ និង អោយតំលៃពេញលេញនៅឡើយទេនៅក្នុងសង្គមកម្ពុជា។



ក្នុងឆ្នាំ២០១៤ គំរោងរបស់អង្គការ អាយស៊ីស៊ីប ហៅថា "សម្លេងកុមារ" បានផ្តល់វគ្គបណ្តុះបណ្តាលស្តីអំពីជំនាញភាពជាឪពុកម្តាយ សិទ្ធកុមារនិង ការការពារកុមារ ដល់អ្នកដឹកនាំព្រះវិហារគ្រីស្ទបរិស័ទ និង ដៃគូរអង្គការក្រៅរដ្ឋាភិបាលចំនួន ១៥០នាក់។ បន្ទាប់ពីបានទទួលវគ្គបណ្តុះបណ្តាលខាងលើពួកគាត់បានបណ្តុះបណ្តាលបន្ត ទៅក្រុមគោលដៅរបស់ពួកគាត់ ដែលមានចំនួនសរុបជាង២០០០នាក់។ មានអ្នកម្តាយជាសិក្ខាកាមម្នាក់បាននិយាយថា *"បន្ទាប់ពីគាត់បានរៀនពីគំរោងហើយ គាត់មានការស្តោយស្តាយចំពោះទង្វើខុសឆ្គងរបស់គាត់កាលពីមុន ក្នុងការប្រៀនប្រដៅ និងចិញ្ចឹមកូន។ គាត់ដឹងថាគាត់ស្រលាញ់កូនគាត់ជាងអ្វីៗ ទាំងអស់តែគាត់មិនចេះប្រើពាក្យល្អៗដើម្បីអប់រំកូនទេ ពេលខឹងម្តងៗមិនចេះទប់អារម្មណ៏ ហើយមិនមានភាពសុក្រិតក្នុងការប្រៀនប្រដៅកូន ពេលខ្លះគាត់បានស្រែកគំហក កុហក បន្ទោសបង្អាប់ ទះ ទាត់ រុញ និង វាយកូនគាត់ "*។ ក្រៅពីគាត់ មានសក្ខាកាមជាច្រើនទៀតដែលមាន ស្ថានភាពស្រដៀងនឹងគាត់ដែរ ប៉ុន្តែតាំងពីពួកគាត់បានយល់ដឹងអំពីសិទ្ធកុមារ ពួកគាត់មានការ ផ្លាស់ប្រែ អកប្បកិរិយារបស់ គាត់ចំពោះកុមារ។ ក្រៅពីការងាររបស់គំរោង"សម្លេងកុមារ" អង្គការអាយស៊ីស៊ីមានគំរោងមួយទៀតហៅកាត់ថា "អាយប៊ីស៊ីឌីអុ " មានទីតាំងនៅខេត្តរតនគីរី និង ខេត្តមណ្ឌលគីរី កំពុងធ្វើការទាក់ទងនឹងសិទ្ធមនុស្សដែរប៉ុន្តែផ្តោតទៅលើសិទ្ធរបស់ជនជាតិភាគតិច។ ជាទូរទៅសហគមន៍ជនជាតិភាគតិច នៅខ្វះការយល់ដឹងអំពីសិទ្ធ ហើយភាគច្រើនពួកគាត់មិនទាន់យល់ដឹងពីច្បាប់ជាតិដែលការពារផលប្រយោជន៍គាត់ ជាពិសេសច្បាប់ទាក់ទងនឹងដីធ្លី សិទ្ធកុមារ និង សិទ្ធជនជាតិភាគតិច។ ដោយសារតែឃើញនូវភាពខ្វះចន្លោះនេះ គំរោងបានសម្របសម្រួលសហគមន៍ជនជាតិភាគតិចអោយធ្វើការឆ្លុះបញ្ចាំងលើ សិទ្ធរបស់ពួកគាត់ ការថែរក្សាវប្បធម៌និងប្រវត្តិសាស្ត្រការការពារព្រៃឈើធម្មជាតិ និងភាសាកំណើត។ ក្នុងឆ្នាំ ២០១៤ គំរោងបានរៀបចំសិក្ខាសាលាជាមួយ សហគមន៍ជនជាតិភាគតិចដើម្បីឆ្លុះបញ្ចាំងអំពីការថែរក្សាវប្បធម៌ និង ការផ្សាភ្ជាប់ទំនាក់ទំនងរវាងជនជាតិដើមជំនាន់មុននិងជំនាន់ក្រោយ។ គំរោងក៏បានផ្តល់សំភារះនិងវិធីសាស្ត្របង្រៀនងាយៗ ជាភាសារជនជាតិភាគតិចដល់គ្រូអក្ខរកម្ម និង បញ្ជ្រាបមូលដ្ឋានសិទ្ធមនុស្សក្នុងនោះដែរ។ មានយុវជនជនខ្លះ មានចំណាប់អារម្មណ៍លើច្បាប់ដូចជា ច្បាប់មូលដ្ឋានសិទ្ធមនុស្ស និងច្បាប់ចរាចរណ៏។ ក្រៅពីនេះ តាមរយះសិក្ខាសាលាយេនឌ័រយើងឃើញថា មានការកើនឡើង នូវការគោរពសិទ្ធរវាងបុរស និងស្ត្រីហើយមានការកាត់បន្ថយ អំពើហឹង្សានៅតាមភូមិគោលដៅមួយចំនួនផងដែរ។

នៅឆ្នាំ២០១៤ អង្គការអាយស៊ីស៊ីបានជ្រើសរើស "សិទ្ធមនុស្ស" ជាការងារឆ្លងវិស័យសំរាប់អង្គភាពរបស់ខ្លួន ហើយកំពុងបង្កើត និងសាកល្បងមេរៀនមួយចំនួនដែលទាក់ទងនឹងមូលដ្ឋានសិទ្ធមនុស្សផងដែរ។

ការរួបរួមគ្នាជាធ្លុងមួយ គឺមានភាពចាំបាច់ណាស់ ក្នុងការរៀបចំ និងជាផ្លូវសម្រាប់ការ លើកម្ពស់ និងការលើកទឹកចិត្តចំពោះការធ្វើការងារជាមួយគ្នា ដើម្បីធ្វើឲ្យសង្គមមួយមាន ភាពចាស់ទុំ និងទទួលបានអត្ថប្រយោជន៍លើផ្នែកសេដ្ឋកិច្ច។ វាពិតជាមាន សារៈសំខាន់ ណាស់ក្នុងការលើកទឹកចិត្ត និងអប់រំណែនាំសហគមន៍ដែលមានប្រាក់ចំណូលទាប ដើម្បី ទទួលស្គាល់ពីសារៈសំខាន់នៃកិច្ចខិតខំប្រឹងប្រែងជារួម លើការដោះស្រាយបញ្ហាមួយដែលបុគ្គលតែម្នាក់ឯងមិនអាចដោះស្រាយបាន។

ឧទាហរណ៍ មានស្ត្រីម្នាក់រស់នៅភូមិអង្គ ក្រសាំង គាត់បានសិក្សាពីអត្ថប្រយោជន៍នៃសាមគ្គីភាពជាក្រុម ដែលវាពិតជាដំណោះ ស្រាយមួយដ៏ល្អបំផុត ដែលគាត់ធ្លាប់បានជួបប្រទះ នៅពេលមានបញ្ហា។ គាត់បានបន្ថែមទៀតថា " *មានកិច្ចខិតខំប្រឹងប្រែងមួយរបស់ក្រុមដែលគួរឲ្យកត់សម្គាល់យ៉ាងខ្លាំង សម្រាប់ ការទទួលបាននូវជោគជ័យ លើការដាំដុះស្រូវ នៅលើវាលស្រែដ៏ហួតហែង។ មានម្តងនោះ មានសមាជិកក្រុម ម្នាក់បានខូចម៉ាស៊ីនបូមទឹក និងមិនមានលទ្ធភាពធ្វើ ប៉ុន្តែដោយមានការរួម ចំណែកក្នុងការចូលរួមជួយគ្នាពីសមាជិកឯទៀតម៉ាស៊ីនរបស់គាត់ក៏ត្រូវបានជួស ជុលរួចរាល់ ហើយគាត់ក៏បានប្រើប្រាស់វាសម្រាប់បូមទឹកដាក់ស្រែដ៏ ហួតហែងរបស់ គាត់ ទាំងក្តីសប្បាយរីករាយ*”។

មានប្រភេទក្រុមជាច្រើនផ្សេងៗគ្នា ដែលគម្រោងរបស់អង្គការអាយស៊ីស៊ីបានបង្កើតឡើង និងបានកំពុងនឹងធ្វើការជាមួយដូចជាក្រុមសន្សំប្រាក់ សហគមន៍កសិកម្មក្រុមផលិតកម្ម កសិកម្ម បណ្តាញសហគមន៍ព្នង ក្រុមយុវជន និងក្រុមសម្របសម្រួលភូមិជាដើម។ សមាជិកក្រុមបាន ប្រមូលផ្តុំនូវធនធានដ៏កម្រ យកមកគ្រប់គ្រងនិងចាត់ចែងដោយពួក គេផ្ទាល់ ដើម្បីដោះស្រាយទៅលើភាពក្រីក្រដែលមានកង្វះខាតស្បៀងអាហារ ភាពទន់ ជ្រាយរបស់បុគ្គលទៅលើភាពគ្មានការងារធ្វើ និងខ្វះការជឿទុកចិត្តលើខ្លួនឯង។ មាន ឧទាហរណ៍មួយពាក់ព័ន្ធនឹងបញ្ហាខាងលើ គឺមានអ្នកមានម្នាក់រស់នៅភូមិមួយក្បែរឃុំរាធរ គាត់បានទប់ទឹកនៅក្នុងត្រពាំងមួយមិនឲ្យហូរចេញក្រៅ ដោយបានធ្វើទំនប់ដ៏ធំមួយ វាធ្វើ ឲ្យទឹកបានជន់លិចស្រូវ ដែលកំពុងលូតលាស់ជាច្រើនហិកតានៅក្បែរនោះ។ សហគមន៍ ដែលរងគ្រោះពីទំនប់នោះមានអារម្មណ៍ថា វាជារឿងមិនត្រឹមត្រូវនោះទេ ម្លោះហើយដោយ មានសហគមន៍កសិកម្មស្រាប់នៅទីនោះពួកគេបានលើកឡើងនូវក្តី កង្វល់នោះទៅក្រុម ប្រឹក្សាឃុំ និងស្រុកហើយសម្លេងរបស់ពួកគេត្រូវបាន អ្នកមានកតព្វកិច្ច ទាំងនោះទទួល ស្គាល់ និងបានដោះស្រាយជូនពួកគាត់ដោយជោគជ័យ។

ការងារអភិវឌ្ឍសហគមន៍របស់អង្គការអាយស៊ីស៊ីនៅភូមិភាគឥសាន្ត នៃប្រទេសកម្ពុជាមានក្រុមពិគ្រោះយោបល់ដែលជាអ្នកកៀងគរ ហើយពួកគេជួយលើកទឹកចិត្តអោយមានសកម្មភាព និងធ្វើអោយពួកគាត់អាចរុករកអោយឃើញនូវបញ្ហា និងតម្រូវការជារួម។ ដូច្នេះហើយអាយស៊ីស៊ី យល់ឃើញថាវាសំខាន់ណាស់ ក្នុងការគាំទ្រសំលេង របស់សហគមន៍ និងគំនិតផ្តួចផ្តើមក្នុងការចាត់វិធានការ។

ក្រុមមួយក្នុងចំណោមក្រុមទាំងអស់ ដែលអាយស៊ីស៊ីបានផ្តល់នូវការគាំទ្រផ្នែកកសាងសមត្ថភាពជាបន្តបន្ទាប់នោះគឺ បណ្តាញសហគមន៍ជនជាតិព្នង ហើយនិងបណ្តាញត្រួតគ្នាមិនផ្លូវការរបស់ខ្លួនផ្សេងទៀតគឺ គណៈកម្មការការពារព្រៃឈើ។ តាមរយៈមធ្យោបាយនេះយើងអាចធ្វើការបានជាមួយសមាជិកសហគមន៍ ដើម្បីជួយកសាងទស្សនវិស័យរបស់ពួកគេអំពីប្រធានបទទាំងអស់ ហើយបន្ទាប់មក ជួយពួកគេអោយ ពិភាក្សាអំពីវិធីដែលអាចអោយ ពួកគេមើលឃើញថាទស្សនវិស័យទាំងនោះអាចកើតឡើងយ៉ាងពិតប្រាកដ។..(តទៅទំព័របន្ទាប់)

## សហគមន៍ "ការចងក្រងគ្នាជាក្រុម"

(តទៅពីទំព័រមុន) យើងក៏បានឃើញដែរថាអ្នកចាស់ទុំនៅក្នុងភូមិស្រែគ្រៀងកំពុងលើកទឹកចិត្តអោយធ្វើការងារជាមួយគ្នា និងជួយគ្នាទៅវិញទៅមក ដោយមាន កំលាំងនិងចិត្តតែមួយ។ នៅឆ្នាំ២០១៤ ពួកគេបានកសាងស្ពានដ៏ធំមួយ ដែលមានប្រវែង៣០ម៉ែត្រ និងស្ពានតូចៗបីបួនទៀត ព្រមទាំងបង្កើតអោយមាន មជ្ឈមណ្ឌលវប្បធម៌សហគមន៍។ មជ្ឈមណ្ឌលនេះ អាចជួយបង្កើតប្រាក់ចំណូលសម្រាប់ ភូមិរបស់ខ្លួនតាម ដែលគេព្រមព្រៀងជាមួយគ្នាថា នៅពេលឈ្នួញឆ្លងស្ពាននេះគេត្រូវបង់ថ្លៃឈ្នួល។ ការនេះវាជួយដល់ផែនការកសាងថ្នាក់អក្ខរកម្ម ការជួសជុលអាគារភូមិក៏អាចនឹងកើតមានឡើងនៅពេលពួកគេរក ប្រាក់ចំណូលបានច្រើន។ និយាយអំពីមជ្ឈមណ្ឌលវប្បធម៌ ភូមិរបស់ពួកគេ, ពួកគេចាប់ផ្តើមបង្រៀនយុវជនអំពីសិល្បៈតម្បាញជនជាតិគ្រឹង។ ចាស់ទុំម្នាក់ក្នុងចំណោមចាស់ទុំនៅក្នុងភូមិស្រែគ្រៀងបាន និយាយថា *"យើងអាចធ្វើអ្វីទាំងអស់នេះបាន ដោយសារគំនិតច្នៃប្រឌិតរបស់យើង និងការប្រវះដៃគ្នា ព្រមទាំងធ្វើការរួមគ្នាក្នុងចិត្ត និងកំលាំងតែមួយ។"* វាជាការសំខាន់មួយ ដែលត្រូវផ្តល់ឱកាស អោយសហគមន៍អាចសាកល្បងគំនិតពួកគេ ដើម្បីមើលឃើញថាតើពួកគេខ្លួនឯងអាចធ្វើអោយបានជោគជ័យរឺក៏អត់ ជាជាងគ្រាន់តែបង្កើតអោយមានជាក្រុម ប៉ុន្តែនឹងបាត់ទៅវិញទៅតាមអង្គការ និងមានការសំរេចចិត្តតែទៅលើបញ្ហាតិចតួច។



## ផែនការឆ្នាំ២០១៥

យើងមាន ការគិតទុកជាមុន យ៉ាងមុតមាំថាក្នុង ឆ្នាំ ២០១៥ យើងនឹង ឈានមួយកំរិតទៀតទាក់ទង នឹងការងារសង្គម ក្នុងន័យធ្វើឲ្យផ្នែកជាច្រើន នៃអង្គការ អាយស៊ីស៊ី បានក្លាយជាអង្គការក្នុងស្រុកដែលស្ថិតនៅក្រោមការដឹកនាំ នៃភាពជាអ្នកដឹកនាំក្នុងស្រុក និងភាពជាម្ចាស់ស្រុក។ លើសពីនេះ តាមរយៈការស្រាវជ្រាវខាងក្នុងរបស់ អាយស៊ីស៊ី នៅឆ្នាំ ២០១៤/ ២០១៥ យើងរំពឹងថានឹងធ្វើការសម្រេចចិត្ត ជាយុទ្ធសាស្ត្រមួយ ថានឹងត្រូវធ្វើយ៉ាងណាលើ ផ្នែកនៃការជួយជនជិតអស់ជីវិត (Palliative Care)។

ទន្ទឹមនឹងនេះដែរ យើងនឹងដឹកនាំឲ្យមានវេទិកានៃការសិក្សា និងពិភាក្សាសម្រាប់សមាជិកភ្នាក់ងារ អាយស៊ីស៊ី និងការគ្រប់គ្រង ឆ្លុះបញ្ចាំងទៅលើចំណុចស្នូលនៃគុណតម្លៃរបស់អង្គការ អាយស៊ីស៊ី។

## សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណចំពោះក្រសួង និងអង្គការខាងក្រោមនេះដែលបានជួយឧបត្ថម្ភគាំទ្រ ដោយចិត្ត សប្បុរស ញ៉ាំងឲ្យការងារ អាយស៊ីស៊ី មានភាពរស់រវើកនៅលើទឹកដីកម្ពុជា៖

ក្រសួងការបរទេស; ក្រសួងអប់រំ យុវជន និងកីឡា; ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនិតិសម្បទា; ក្រសួងអភិវឌ្ឍន៍ជនបទ; ក្រសួងសុខាភិបាល; InterAct; Cambodia Action; SIL International; Normisjon; Viator; Digni; FELM; Tearfund UK; TEAR Australia; Danmission; Transform Aid Int; LEAD Asia; ECHO Asia; EFC; CCC; MEDICAM; Micah Network; NGO Education Partnership; MRO និង PFC




ការិយាល័យកណ្តាល

ផ្ទះលេខ ១C ភូមិត្នោតជ្រុំ ផ្លូវ៣៧១ កែងនិង២៦បេតេ

សង្កាត់បឹងទំពន់

ខណ្ឌមានជ័យ

ទូរស័ព្ទលេខ៖ ០៩២ ៤៦៩ ៩៣៤

អ៊ីមែល៖ info@icc.org.kh,

គេហទំព័រ៖ www.icc.org.kh